**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ១០៣/២៥ ក.ប/ប្រ.ក.ស.ក.ក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងការិយការី

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីលក្ខណៈការងារនៃការិយការី និងកាតព្វកិច្ចពាក់ព័ន្ធនឹងការប្រើប្រាស់កម្មករនិយោជិតតាមរយៈកិច្ចសន្យាជួលការិយការី ក្នុងគោលបំណងធានានូវអត្ថប្រយោជន៍របស់កម្មករនិយោជិត។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ:(០២៣)៨៨២៧៦៩

**ប្រការ២ .–**

ការិយការីសំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលការងារពីសហគ្រិនជាសហគ្រាស គ្រឹះស្ថានដើម ក្នុងនាមជាអ្នកម៉ៅការបន្ត ឬអ្នកជួលផលិតបន្ត ដើម្បីប្រតិបត្តិការងារ ឬផ្តល់សេវាណាមួយដោយគិតថ្លៃសរុបពីសហគ្រិន តាមរយៈការជ្រើសរើសកម្មករនិយោជិតដោយខ្លួនឯងតាមតម្រូវការ ទោះបីជាប្រតិបត្តិការងារនៅទីតាំងណាមួយក៏ដោយ។

**ប្រការ៣ .–**

កិច្ចសន្យាជួលការិយការី ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវចុះបញ្ជីនៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសហគ្រិន។

**ប្រការ៤ .–**

សហគ្រិនដែលជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវរៀបចំបញ្ជីរាយនាមការិយការី ដែលបានចុះកិច្ចសន្យាជាមួយ ដោយមានបញ្ជាក់នាម ឋានៈ អាសយដ្ឋាននៃការិយការី និងស្ថានភាពនៃទីកន្លែងធ្វើការនីមួយៗ ព្រមទាំងបញ្ជីឈ្មោះកម្មករនិយោជិត ដែលការិយការីប្រើប្រាស់តាមទម្រង់ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ដោយត្រូវផ្ញើបញ្ជីនោះមកអធិការការងារ តាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ ដែលមានគេហទំព័រ https://lacms.mlvt.gov.kh/ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ ចំពោះសហគ្រាសទូទៅ និង១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសហគ្រាសកសិកម្ម ក្រោយថ្ងៃចុះកិច្ចសន្យា។

**ប្រការ៥ .–**

ការិយការីមានកាតព្វកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះកម្មករនិយោជិត ដែលខ្លួនជ្រើសរើសក្នុងការអនុវត្តកិច្ចសន្យាជួលការិយការីដូចនិយោជកដែរ
- ចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ តាមគេហទំព័រ https://lacms.mlvt.gov.kh/ និងរាយការណ៍អំពីនាម អាសយដ្ឋាន របស់សហគ្រាស គ្រឹះស្ថានដើមដែលខ្លួនបានចុះកិច្ចសន្យាជាមួយ ព្រមទាំងចុះបញ្ជីក្នុងបេឡាជាតិសន្តិសុខសង្គម
- បិទប្រកាសបញ្ជាក់នៅកន្លែងធ្វើការ ឬការដ្ឋាននីមួយៗ ដែលអាចងាយអានបាននូវឋានៈរបស់ខ្លួន និងនាម អាសយដ្ឋាននៃសហគ្រាស គ្រឹះស្ថានដើមដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៦ .–**

កម្មករនិយោជិតអាចប្តឹងម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដើម ក្នុងករណីការិយការីមិនបានបំពេញកាតព្វកិច្ចដែលធ្វើឱ្យខូចប្រយោជន៍របស់ខ្លួន។

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដើមត្រូវទទួលខុសត្រូវបំពេញកាតព្វកិច្ចចំពោះកម្មករនិយោជិត ក្នុងករណីដែលការិយការីមិនអាច ឬមិនបានបំពេញកាតព្វកិច្ចទាំងនោះ។

**ប្រការ៧ .–**

ការកេងយកប្រយោជន៍ពីកម្មករនិយោជិត ឬការវាយបន្ថោកថ្លៃដោយការិយការីត្រូវហាមឃាត់។

**ប្រការ៨ .-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងការដាក់ពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ០ខ្ទុ ២កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ......១០៣/២៥......ក.ប/ប្រក.ន.ក.ក...ចុះថ្ងៃទី..២៨......ខែមេសា.....ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រងការិយការី

## បញ្ជីឈ្មោះកម្មករនិយោជិតដែលការិយការីប្រើប្រាស់

**ឈ្មោះការិយការីដែលសហគ្រិនប្រើប្រាស់**.................................................................**ជាអក្សរឡាតាំង**.......................................
**អាសយដ្ឋាន អគារ**.................**ភូមិ**..........................**ឃុំ/សង្កាត់**.......................................**ស្រុក/ខណ្ឌ**.......................................**ខេត្ត/រាជធានី**.......................................
**សកម្មភាពអាជីវកម្ម**.................................................................................................................................
**ឋានៈ/តួនាទីការិយការី**.............................................................................................................................
**ផ្នែកការងារ** ...................................................................................**ផលិតផលម៉ាក (ប្រសិនបើមាន)**.......................................
**រយៈពេលកិច្ចសន្យាជួលការិយការី ចាប់ពីថ្ងៃទី**.......... **ខែ**.............. **ឆ្នាំ**.............. **ដល់ ពីថ្ងៃទី**......... **ខែ**.............. **ឆ្នាំ**.............. **ថ្លៃឈ្នួលសរុប (គិតជាដុល្លារ)**..........................................
**ចំនួនកម្មករនិយោជិតសរុបដែលការិយការីប្រើប្រាស់**...........................**ស្រី**...................... (**ចំនួនកម្មករនិយោជិតបរទេសសរុបដែលការិយការីប្រើប្រាស់**.................. **ស្រី**..................)
**ឈ្មោះតំណាងការិយការី**..........................................**លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ/លេខលិខិតឆ្លងដែន**........................................ **លេខទូរស័ព្ទ**..................................

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លេខលិខិតឆ្លងដែន | លេខបណ្ណសមាជិក ប.ស.ស. | មុខងារ | សញ្ជាតិ | លេខទូរស័ព្ទ | ប្រាក់ឈ្នួល (គិតជាដុល្លារ) | ថ្ងៃ ខែ ឆ្នាំចូលធ្វើការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

បញ្ចប់ត្រឹមលេខរៀងទី..... ឈ្មោះ..................

ថ្ងៃទី............ ខែ............. ឆ្នាំ២០២.....
**ឈ្មោះ ហត្ថលេខា និងត្រា**
**ម្ចាស់ ឬនាយក**

**សម្គាល់៖** សហគ្រាស គ្រឹះស្ថានត្រូវបោះត្រានៅគ្រប់ទំព័រលើបញ្ជីឈ្មោះនេះ រួចត្រូវផ្ញើបញ្ជីនេះ ជា Excel File និងស្កេនបញ្ជីឈ្មោះដែលបោះត្រានៅគ្រប់ទំព័រជា PDF File មកក្នុងប្រព័ន្ធ LACMS

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...១៨៣/២៥ ក.ប/ប្រ.ក.ខ.ក.ត ចុះថ្ងៃទី..២៨.......ខែ..មេសា.....ឆ្នាំ២០២៥
ស្ដីពីការគ្រប់គ្រងការិយភារី

# សេចក្ដីប្រកាសឋានៈរបស់ការិយភារី

## I-ព័ត៌មានរបស់សហគ្រិន

ឈ្មោះសហគ្រិន ........................................................................................................

ជាអក្សរឡាតាំង ........................................................................................................

អាសយដ្ឋាន អគារ..............ភូមិ.........................................ឃុំ/សង្កាត់..................................................

ស្រុក/ខណ្ឌ...................................................ខេត្ត/រាជធានី ..................................................................

សកម្មភាពអាជីវកម្ម ..................................................................................................

ឈ្មោះម្ចាស់សហគ្រាស គ្រឹះស្ថាន........................................... លេខទូរស័ព្ទ ..................................

ឈ្មោះរដ្ឋបាល.................................................. លេខទូរស័ព្ទ ..................................................

## II-ព័ត៌មានរបស់ការិយភារី

ឈ្មោះការិយភារីដែលសហគ្រិនប្រើប្រាស់ ........................................................................

ជាអក្សរឡាតាំង ........................................................................................................

អាសយដ្ឋាន អគារ..............ភូមិ.........................................ឃុំ/សង្កាត់..................................................

ស្រុក/ខណ្ឌ...................................................ខេត្ត/រាជធានី ..................................................................

សកម្មភាពអាជីវកម្ម ..................................................................................................

ឋានៈ/តួនាទីការិយភារី..................................................................................................

ផ្នែកការងារ ..............................................................................................................

ផលិតផលម៉ាក (ប្រសិនបើមាន) ..................................................................................

រយៈពេលកិច្ចសន្យាជួលការិយភារី ចាប់ពីថ្ងៃទី........ ខែ......... ឆ្នាំ......... ដល់ ពីថ្ងៃទី....... ខែ.......... ឆ្នាំ ........

ចំនួនកម្មករនិយោជិតសរុបដែលការិយភារីប្រើប្រាស់ ..............................ស្រី ....................................

ចំនួនកម្មករនិយោជិតបរទេសសរុបដែលការិយភារីប្រើប្រាស់.............................ស្រី............................... )

ឈ្មោះតំណាងការិយភារី ..............................................................................................

លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ/លេខលិខិតឆ្លងដែន.............................. លេខទូរស័ព្ទ ..................

ថ្ងៃទី............ ខែ.............. ឆ្នាំ២០២.....

**ឈ្មោះ ហត្ថលេខា និងត្រារបស់ការិយភារី**